## សិក្សាអត្ថបទរបស់លោក NAYAN CHANDA ក្នុងសៀវភៅ BROTHER ENEMY

# ទំនាក់ទំនង ចិន-វៀតណាម-សីហនុ

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី២៥ មករា ២០០៥

★ សីហនុចង់បានគុណស្រ័យពីវៀតណាម ៖

ហេតុអ្វីបានជាស្តេចសីហនុចិញ្ចឹមបំប៉នយៀកកុងនៅក្នុងទឹកដីកម្ពុជា នាសតវត្សរ៍១៩៦០ ឲ្យច្បាំងតតាំងជាមួយសហរដ្ឋអាមេរិក ?...យោងតាមសំណេររបស់លោក ណាយ៉ាន់-ចាន់ដា គឺមកពីរស្តេចសីហនុចង់ទទួលសរគុណពីសត្រូវស្នូរពូជ (យួន) ។ បើដូច្នេះមែន ស្តេចសីហនុបានត្រឹមតែដើរតាមគន្លងធម៌របស់ស្តេចខ្មែរ ស្ទើរតែទាំងអស់ នៅក្នុងយុគសម័យនៃកម្ពុជាធ្លាក់ដុនដាប (ក្រោយសម័យអង្គរ មកទល់សព្វថ្ងៃ ពោលជាង៦០០ឆ្នាំមកហើយ) ។ ព្រះសត្ថាទី១ (១៥៧៦-១៥៩៦) បានជួយសៀមឲ្យច្បាំងឈ្នះប្រទេសភូមា... លុះសៀមសងគុណវិញ ក៏ត្របាក់យកដីខ្មែរអស់មួយភាគ ៖ ខេត្តសុរិន, បូរីរុំ, ស៊ីសាកេត...។ ស្តេចជ័យជេដ្ឋាទី២ (១៦១៨-១៦២៨) ហេតុតែចង់បានសរគុណពីយួន ក៏បានអនុញ្ញាតឲ្យយួនមកតាំងនៅក្នុងដីព្រៃនគរ... រួចហើយខ្មែរត្រូវបានបង់ទឹកដីកម្ពុជាក្រោមជាស្ថាពរ ។

លុះដល់ស្តេចសីហនុក្នុងសតវត្សរ៍ទី២០វិញ គឺបានចិញ្ចឹមយៀកកុង-យៀកណាមខាងជើង ឲ្យធំធាត់នៅភូមិភាគខាងកើតនៃកម្ពុជា... គឺគ្រាន់តែអនុញ្ញាតឲ្យពួកនេះវាតដីខ្មែរកណ្តាលអស់រលីង តាំងពីខាងកើតទៅដល់ខាងលិច រហូតទៅដល់ទល់ដែនសៀម ។ នៅក្នុងឆ្នាំ១៩៤២ ពេលស្តេចសីហនុសរសេរសំបុត្រទៅប្រាប់ផាំ-យ៉ាំងដុង ឲ្យយួនដកថយពីកម្ពុជា ជននេះមិនទាំងបានហែកលិខិតរបស់ស្តេចខ្មែរដើម្បីអានផង...

យោងតាមលោក ណាយ៉ាន់-ចាន់ដា «នៅពេលដែលសង្គ្រាមកំពុងឡើងកំសួលពេញបន្ទុកនៅវៀតណាម នៅក្រោយឆ្នាំ១៩៦៥... ពួកយៀកកុងនិងយៀកណាមខាងជើងត្រូវការទីជំរកនៅប្រទេសកម្ពុជា ព្រមទាំងអាវុធយុទ្ធភ័ណ្ឌ លើសពេលណាៗទាំងអស់ - សេចក្តីត្រូវការមួយដែលសម្តេចសីហនុមានសុឆន្ទៈនឹងបំពេញ យ៉ាងស្ងៀមស្ងាត់ នៅក្រោមផ្លាកនៃអព្យាក្រឹត្យភាព ។ បើទោះជាសីហនុកំពុងធ្វើការបង្ក្រាបលើពួកខ្មែរក្រហមដោយដៃដែកយ៉ាងណាក្តី ទ្រង់បានប្រកាសថា ទ្រង់មានចំណូលចិត្តយ៉ាងខ្លាំង ជាមួយពួកវៀតណាមកុម្មុយនិស្ត ។ នៅពេលដែលទ្រង់ដាក់ទោសពួកកុម្មុយនិស្តឡូកាល់ (ខ្មែរក្រហម) ថាជាពួកភ្នាក់ងារហាណូយនិងប៉េកាំង ទ្រង់បានចាត់ទុកថា សង្គ្រាមវៀតណាមមានខ្លឹមសារជាសង្គ្រាមស្នេហាជាតិ តទល់នឹងអន្តរាគមន៍ដ៏អយុត្តិធម៌មកពីបរទេស ។ ដូចថ្ងៃក្រោយមក ទ្រង់បានសារភាពនៅក្នុងសំណេរអនុស្សាវរីយ៍របស់ព្រះអង្គ... ស្តេចបានបិទភ្នែកចំពោះជំរំទីតាំងរបស់វៀតណាម អំពីមន្ទីរពេទ្យ អំពីឃ្លាំងដាក់គ្រឿងឧបភោគ-បរិភោគយៀកកុង នៅប្រទេសកម្ពុជា ។ ទ្រង់បានអនុញ្ញាតឲ្យនាវាចិន, សូវៀត, ឆេកូ និងរបស់ប្រទេសសង្គមនិយមដទៃជាច្រើនទៀត ឲ្យដឹកស្បៀងនិងអាវុធសំរាប់ប្រគល់ឲ្យយៀកកុង រហូតមកដល់ក្រុងព្រះសីហនុ ហើយដែលត្រូវដឹកជញ្ជូនយ៉ាងស្ងៀមស្ងាត់ ឆ្ពោះទៅព្រំប្រទល់ដែនយួន ដោយទុកមួយភាគយ៉ាងតូចសំរាប់កងទ័ពខ្មែរ» ។

«ចំណង់របស់សីហនុ ក្នុងប្រការជួយស្នួយវៀតណាមកុម្មុយនិស្តដូច្នេះ គឺមកពីព្រះអង្គមានព្រះតម្រិះយ៉ាងវ័យឆ្លាត ថាទ្រង់នឹងបានទទួលភាគចំណេញ ពីពួកអ្នកដែលទទួលជ័យជំនះជាយថាហេតុ ។ «បុព្វហេតុដែលជំរុញឲ្យខ្ញុំធ្វើសហការជាមួយវៀតណាម», សីហនុថ្លែងនៅថ្ងៃក្រោយមក «គឺខ្ញុំត្រូវធ្វើយ៉ាងណា ឲ្យវៀតណាមកុម្មុយនិស្តជំពាក់គុណកម្ពុជាយ៉ាងខ្លាំង រហូតដល់ពួកនេះលែងហ៊ានលើកដៃបំផ្លិចបំផ្លាញប្រទេសជាតិយើង, ប្រជាជនយើង ដែលជាអ្នកមានគុណទៅលើពួកគេគេ»...។

«ប្រហែលជាទ្រង់ភ័យខ្លាចថា ពួកវៀតណាមខាងជើងនឹងមានលទ្ធភាពបំផ្លិចបំផ្លាញទ្រង់ ឧបមាបើទ្រង់ហ៊ានប្រឆាំងនឹងការប្រយុទ្ធរបស់ពួកគេក៏មិនដឹង ។ ស្តេចជឿជាក់ច្បាស់ណាស់ថា ចិនហើយនិងវៀតណាមច្បាស់ជានឹងក្លាយទៅជា កត្តានៃជ័យជំនះមួយយ៉ាងធំ នៅក្នុងភពអាស៊ីនៅពេលដែលអាមេរិកាំងដកថយចេញទៅ ។ នៅក្នុងខែសីហា១៩៦៣ សីហនុផ្តាច់ទូតពីវៀតណាមខាងត្បូង ហើយបន្ទាប់មកបាន«ទាត់»ជំនួយសេដ្ឋកិច្ចនិងយោធាសំរាប់កម្ពុជាពីសហរដ្ឋអាមេរិក ។ នៅក្នុងខែឧសភា១៩៦៥ ប្រទេសកម្ពុជាបានផ្តាច់ចំណងទូតទាំងអស់ពីក្រុងវ៉ាស៊ិនតោន សកម្មភាពមួយដែលបានទទួលការសរសើរយ៉ាងខ្លាំងពីក្រុងប៉េកាំងនិងហាណូយ ហើយនៅខែមិថុនានៃឆ្នាំដដែលនោះ ទ្រង់ក៏បង្កើនការគាំទ្រដល់ពួកយៀកកុង ដោយផ្តល់ជំនួយមន្ទីរពេទ្យ ។ ទ្រង់បានប្រកាសក្នុងខែវិច្ឆិកា១៩៦៥ថា «អាមេរិកាំងអាចពិឃាតជនវៀតណាម ពី១០ទៅ២០លាននាក់បាន ។ ប៉ុន្តែយូរនិងឆាប់... ពួកនេះកាន់តែបោះបង់ចោលវៀតណាមទៅឲ្យពួកអ្នកឈ្នះ... សហរដ្ឋអាមេរិកបានលោតចូលខ្លួនឯងទៅក្នុងការផ្សងព្រេងមួយ ដែលចុងចប់ទៅនឹងក្លាយ ដោយចៀសវាងមិនរួចទៅជាការបរាជ័យ» ។

«កាលសម័យនោះ, វៀតណាមមានការដឹងគុណចំពោះសីហនុពិតមែន, ហើយគ្មានអ្វីគួរចម្លែកទេ ដែលនៅក្នុងខែក្តៅនៃឆ្នាំ១៩៦៥ នៅពេលដែលប៉ុល-ពតធ្វើទស្សនកិច្ចសម្ងាត់នៅហាណូយ មុននឹងឆ្លងកាត់ទៅប្រទេសចិន, វៀតណាមបានជំរុញឲ្យមេខ្មែរក្រហមម្នាក់នេះ គាំទ្រនយោបាយក្រៅប្រទេសរបស់ស្តេចសីហនុ ដែលប្រឆាំងនឹងចក្រពត្តិនិយម ។ ប្រសិនបើពួកខ្មែរក្រហមងើបឡើងច្បាំងនឹងរដ្ឋាភិបាលរបស់សម្តេចសីហនុ វានឹងអាចបណ្តាលឲ្យខូចខាតដល់កម្មវិធីយុទ្ធសាស្ត្រវែងឆ្ងាយរបស់វៀតណាម ។ ហាណូយមិនបានយល់ថា ទង្វើដូចនេះពុំមែនជាការបង្ខំឲ្យកម្ពុជាចុះញ៉ម ដើម្បីបំរើសេចក្តីត្រូវការរបស់វៀតណាមនោះឡើយ តែពួកគេជឿជាក់ថា ពេលវេលាមិនទាន់មកដល់សំរាប់កម្ពុជាដើម្បីធ្វើសង្គ្រាមវណ្ណៈទល់នឹងវណ្ណៈនោះឡើយ» ។

(Brother Enemy, p.61-62)

❑

★ សីហនុជាភ្នាក់ងាររបស់ចិន ឬក៏ជាភ្នាក់ងាររបស់យួន ?

មហាក្សត្រខ្មែរច្រើនតែនាំស្នួយសារអាករ ទៅថ្វាយអធិរាជកណ្តាល (ចិន) កាលសម័យអង្គរ ក្នុងប្រការឲ្យចិនជួយការពារបូរណភាពទឹកដី ។ មធ្យោបាយនេះមិនបានសំរេចទេ ដោយប្រទេសចិនធ្លាក់ចូលក្នុងឱនភាពធ្ងន់ធ្ងរ បណ្តាលមកពីកល្លិយុគផ្ទៃក្នុង ។ តើប្រទេសចិនការពារប្រទេសក្រៅឯណាបាន បើចិនការពារតែខ្លួនឯងមិនបានផង តទល់នឹងការវាយលុករបស់ពួកម៉ុងគោ្គល ។ នៅសម័យអនាធិបតេយ្យរីករវនៃការធ្លាក់ដុនដាបរបស់មហារាជចិន... មហារាជកម្ពុជាក៏បានធ្លាក់ដុនដាបជាមួយ

គ្នាផងដែរ ដោយប្រទេសចំប៉ាបានលើកទ័ពមកវាយបំផ្លិចបំផ្លាញនគរខ្មែរ ព្រមទាំងដុតក្រុងអង្គរឆេះខ្ទេចខ្ទី នៅក្នុងសម័យចុងចប់នៃស្តេចខ្មែរដ៏ឆ្នើម សុរិយាវរ្ម័នទី២ ។ បន្ទាប់មកប្រទេស«អណ្ណាម» (ជាពាក្យចិនដែលមានន័យថា «ទឹកដីខាងត្បូងដែលមានសន្តិភាព») ក៏បានប្រឆាំងនឹងអាជ្ញារបស់មហារាជកណ្តាល ដោយបានវាយកំទេច ហើយ«លេប»ទឹកដីប្រទេសចំប៉ា ព្រមទាំងបានចាប់ផ្តើម«លេប»ទឹកដីកម្ពុជាក្រោមនៅក្នុងរជ្ជកាលនៃព្រះជ័យជេដ្ឋាទី២ ។

ដូច្នេះ តាំងពីសម័យយុគកណ្តាលមក ស្តេចខ្មែរច្រើនតែជាមនុស្សរបស់យួន ពុំមែនជាមនុស្សរបស់ចិនទៀតទេ ។ ចំណែកស្តេចសីហនុវិញក៏ជាទីងមោងរប-ស់យួនដូចគ្នាដែរ... បើយោងតាមសំណេររបស់លោក ណាយ៉ាន់-ចាន់ដា នៅក្នុង សៀវភៅ Brother Enemy ដដែល ។ ថ្វីបើមានប្រទេសចិនជួយផ្គងផ្តើមស្តេចខ្មែរគ្រប់ជំហាន ឲ្យប្រទេសស្នាក់នៅ មើលថែទាំតាំងពីជម្ងឺប្រចាំកាយ (ជាការចំឡែក តាមភ្នែកពួកសាធារណរដ្ឋខ្មែរ... សីហនុជាមនុស្សរបស់យួនផង របស់ចិនផង... តែតាមភ្នែករបស់ពួកខ្មែរក្រហមវិញ សីហនុជាមនុស្សរបស់យួនសុទ្ធសាធ) ។

តទៅនេះ ជាអត្ថបទរបស់លោក ណាយ៉ាន់-ចាន់ដា ដែលបង្ហាញថាការចាក់សាំងដុតប្រទេសកម្ពុជា ក្រោយព្រឹត្តិការណ៍១៨មិនា១៩៧០ ជាស្នាដៃរបស់វៀតណាមនិងស្តេចទីងមោងសីហនុ ។ ចំណែកចិនគ្រាន់តែដើរតាមក្រោយគន្លងធម៌របស់វៀតណាមប៉ុណ្ណោះ ៖

«បន្ទាប់ពីមានបាតុកម្មប្រឆាំងវៀតណាមនៅភ្នំពេញ ហើយនិងការវាយបំផ្លាញទូតវៀតណាមខាងជើងដោយក្រុមនិស្សិតមួយហ្វូង, រដ្ឋសភាដែលមានតំណាងរាស្ត្រភាគច្រើនជាពួកស្តាំនិយម ក៏បានទម្លាក់សម្តេចពីតំណែង (១៨មិនា១៩៧០) ហើយក៏បានប្រគល់អំណាចទៅឧត្តមសេនិយលន់-នល់ រដ្ឋមន្ត្រីទី១ ដែលទទួលបន្ទុកផ្នែកក្រសួងការពារប្រទេសផងដែរ ។ សម្តេចសីហនុពេលនោះស្ថិតនៅទីក្រុងម៉ូស្គូ កំពុងរៀបចំជិះយន្តហោះឆ្ពោះទៅក្រុងប៉េកាំង ដែលនឹងក្លាយទៅជាលំនៅទី២របស់ទ្រង់ ។

«រដ្ឋប្រហារទម្លាក់ស្តេចសីហនុ លេចឡើងជាការគំរាមកំហែងដល់ពួកខាងឆ្វេងផ្ទៃក្នុងកម្ពុជា (ខ្មែរក្រហម)ផង និងដល់ជំរំយៀកកុងផងដែលអាចដាច់ស្បៀងរបស់ខ្លួន ។ គឺព្រឹត្តិការណ៍តែមួយនេះសោះដែលជំរុញឲ្យវៀតណាមនិងខ្មែរក្រហម ចងសម្ព័ន្ធមេត្រីដ៏លំបាកមួយដើម្បីប្រឆាំងនឹងសត្រូវរួម គឺរដ្ឋាភិបាលលន់-នល់ ដែលគាំទ្រដោយអាមេរិកាំង ។ កត្តាសំខាន់នៅក្នុងចំណងមិត្តភាពថ្មីនេះ គឺរូបបុគ្គលរបស់សម្តេចសីហនុដែលគេបានទម្លាក់ នៅពេលដែលពួកខ្មែរក្រហមត្រូវការព្រះនាមទ្រង់ មកធ្វើជារនាំងតាមផ្លូវច្បាប់ ដើម្បីបិទបាំងសកម្មភាពរបស់ពួកខ្លួនតាមផ្លូវអន្តរជាតិ ព្រមទាំងទាក់ទាញប្រជាកសិករក្នុងស្រុក ឲ្យចុះចូលបានកុះករផង ។ ពួកវៀតណាមឯណោះវិញ បានមើលឃើញរូបភាពសម្តេច មិនមែនត្រឹមតែជាសសរទ្រូងក្នុងការតស៊ូប្រឆាំងនឹងសហរដ្ឋអាមេរិកនិងលន់-នល់ប៉ុណ្ណោះទេ ក៏ប៉ុន្តែគេបានចាត់ទុកថា ទ្រង់ជាការធានាអះអាងសំខាន់មួយទៀត ក្នុងប្រការគ្របសង្កត់ទៅលើអំណាចពួកក្រុមខ្មែរក្រហម ដែលដឹកនាំដោយប៉ុល-ពត ។

«ផ្ទុយទៅវិញ គេបានឃើញថា គោលជំហរនៃប្រទេសចិនមានលក្ខណៈមិនច្បាស់លាស់សោះនៅក្នុងរឿងខាងលើ ។ សីហនុបានបដិសេធនូវការវិភាគមួយ ដែលហាណូយនិងប្រទេសខាងលិចខ្លះយល់ថាជាការត្រឹមត្រូវ... ថាប្រទេសចិន ពីដំបូងទីមានការស្ទាក់ស្ទើរក្នុងការគាំទ្រទ្រង់ ។ «ពេលយើងជួបគ្នាដំបូង (ថ្ងៃ១៩មិនា) នៅក្នុងដំណាក់របស់ខ្ញុំ», ស្តេចសីហនុពោល «លោកជូ-អេនឡាយនិងខ្ញុំ បានព្រមព្រៀងថាដំណើរនៃរដ្ឋប្រហារ ដែលគេចាត់ទុកថាជាអំពើមួយប្រព្រឹត្ត រួចស្រេចបាច់ទៅហើយនោះ (ដូចអង្ករក្លាយទៅជាបាយ) មិនត្រូវទទួលយកបានទេ ។ យើងត្រូវតែប្រឆាំងនឹងអំពើខុសច្បាប់នេះ រហូតដល់ចុងចប់» ។ ក៏ប៉ុន្តែលោកជូ-អេនឡាយមិនបានជំរុញស្តេចសីហនុ ឲ្យទៅចូលជាមួយនឹងពួកខ្មែរក្រហមនោះឡើយ ។ យោងតាមស្តេចសីហនុ លោករដ្ឋមន្ត្រីទី១ចិន គ្រាន់តែពាំនាំយកសារលិខិតមួយរបស់លោកប្រធានម៉ៅមកបង្ហាញ ហើយដែលមានសេចក្តីដូចតទៅនេះ ៖

«ប៉េកាំងនឹងមានការគោរពយ៉ាងហ្មត់ចត់ នូវសេចក្តីសំរេចរបស់សម្តេចនរោត្តម-សីហនុ ។ បើទ្រង់ចង់បញ្ចប់ជីវិតនយោបាយរបស់ទ្រង់ ដោយសារតែមានរដ្ឋប្រហារកាលពីថ្ងៃម្សិល ប្រទេសចិននឹងច្បាស់ជាអនុលោមទៅតាមសេចក្តីសំរេចនេះ ។ ក៏ប៉ុន្តែបើសម្តេចសីហនុ មិនព្រមទទួលយកលទ្ធផលចុងចប់នៃរដ្ឋប្រហារនេះ ហើយសំរេចថានឹងដឹកនាំចលនាស្នេហាជាតិ ច្បាំងប្រយុទ្ធតស៊ូប្រឆាំង នឹងអាមេរិកាំងដើម្បីរំដោះប្រទេសកម្ពុជា ប្រទេសចិននឹងធ្វើការគាំទ្រសម្តេចសីហនុជាមិនខាន ព្រមទាំងផ្តល់ទ្រង់នូវជំនួយគ្រប់បែបយ៉ាង» ។

ការអធិប្បាយរបស់សម្តេចសីហនុផ្ទាល់ ក៏អាចពន្យល់បាន ថាហេតុអ្វីបាន ជាក្រុងប៉េកាំងបានរក្សាទំនាក់ទំនងអស់ មួយរយ:ពេលជាមួយនិងរបបលន់នល់។ ជាការពិតណាស់ ប្រទេសចិនមិនបានចង់ផ្តាច់ចំណងមេត្រីពីភ្នំពេញភ្លាមៗ ពីព្រោះចិនត្រូវការរកមធ្យោបាយអ្វីផ្សេង (ដាក់សម្តេចសីហនុឲ្យចូលកាន់អំណាចវិញ) ក្រៅពីមធ្យោបាយនៃការធ្វើសង្គ្រាម ។ ម្យ៉ាងវិញទៀត រដ្ឋប្រហារភ្នំពេញបានប្រព្រឹត្តឡើង នៅក្រោយពេលបន្ទាប់ពីប្រទេសចិន មានការប៉ះទង្គិចគ្នាយ៉ាងខ្លាំង ខាងផ្នែកយោធានៅតាមបណ្តោយព្រំប្រទល់ជាមួយនិងសហភាពសូវៀត ។ ម្ល៉ោះហើយក្រុងប៉េកាំងកំពុងតែសម្លឹងរកមើលលទ្ធភាពសំរុះសំរួលសភាពការណ៍ពោលរីតចំណងមេត្រីជាមួយក្រុងវ៉ាស៊ិនតោន ។ ក្នុងប្រការនេះ ធ្វើសង្គ្រាមជាមួយលោកលន់-នល់ គឺច្បាស់ជានឹងបង្កើតឧបសគ្គដល់ចំណងមេត្រីជាពុំខាន ។

«នៅពេលក្រោយមក ការឃោសនារបស់ហាណូយបានអះអាងថាក្រុងប៉េកាំងបានស៊ីគ្រលុំជាមួយនឹងរបបលន់-នល់ ក្នុងគោលបំណងកុំឲ្យពួកយៀកកុងទទួលជ័យជំនះនៅវៀតណាមខាងត្បូង ។ អ្នកនាំពាក្យដ៏សំខាន់បំផុតរបស់គណបក្សកុម្មុយនិស្តវៀតណាម លោកហួង-ទុងបានប្រាប់ខ្ញុំ (ណាយ៉ាន់-ចាន់ដា) នៅខែក្រោយខែមិនា១៩៧០ ថាពួកចិនមិនសូវជាសប្បាយចិត្តនឹងស្តេចសីហនុប៉ុន្មានទេ ដែលបានធ្វើការតិទៀនចំពោះលោកប្រធានម៉ៅ កាលពីយុគសម័យបដិវត្តន៍វប្បធម៌ ។

«ចំណែកពួកសមមិត្តកុម្មុយនិស្តរបស់យើងនៅកម្ពុជា», លោកទុងពោល «បានចិញ្ចឹមចិត្តស្អប់ខ្ពើមស្តេចសីហនុយ៉ាងខ្លាំង ពីព្រោះតែទ្រង់បានពិឃាតពួកគេយ៉ាងរង្គាល ។ ស្តេចសីហនុបានសម្លាប់ពួកកុម្មុយនិស្តច្រើនណាស់ ពីចន្លោះឆ្នាំ១៩៥៥ទៅ១៩៦៥ ។ នៅពេលដែលសីហនុបានមកដល់ប៉េកាំង (ក្នុងខែមិនា១៩៧០) ទាំងជូ-អេនឡាយ ទាំងប៉ុល-ពត ពុំបានធ្វើអ្វីទាំងអស់ ដើម្បីទាក់ទាញយកស្តេចសីហនុ មកធ្វើមេដឹកនាំតស៊ូ ។ គឺពួកយើងទេវិញទេ ពួកវៀតណាមដែលបានចាត់វិធានការណ៍នេះ ។ ផាំ-យ៉ាំងដុង (ដែលបានដឹកនាំប្រតិភូសម្ងាត់មួយទៅប៉េកាំងបីថ្ងៃក្រោយរដ្ឋប្រហារ) ជាអ្នកមានភារកិច្ចខាងញ៉ាំងជូ-អេនឡាយ, ចំណែក ផាំ-ហ៊ុង (សមាជិកគណ:កម្មាធិការកណ្តាលម្នាក់ដែលធ្វើដំណើរជាមួយផាំ-យ៉ាំងដុង) មានភារកិច្ចញ៉ាំងប៉ុល-ពត» ។

«ស្តេចសីហនុខ្លួនឯងបានសារភាពថា ទ្រង់បានទទួលការលើកទឹកចិត្តពីផាំ-យ៉ាំងដុងដោយផ្ទាល់ ។ នៅថ្ងៃទី២៣មិនា, ថ្ងៃបន្ទាប់ពីបានជួបសន្ទនាជាមួយផាំ-យ៉ាំងដុងយ៉ាងយូរ, ស្តេចសីហនុក៏បានធ្វើសេចក្តីប្រកាសតាមវិទ្យុប៉េកាំង ឲ្យខ្មែរងើបឡើងធ្វើការតស៊ូ (ចូលព្រៃម៉ាគី) ។ នៅ

ថ្ងៃស្អែកឡើង មុននឹងចាកចេញពីទីក្រុងប៉េកាំង, ផាំ-យ៉ាំងដុងបានផ្ញើលិខិតមួយសរសេរដោយដៃទៅសីហនុ មានសេចក្តីដូច្នេះថា ៖ «ខ្ញុំសូមសំដែងនូវមនោសញ្ចេតនាមិត្តភាពដ៏ជ្រាលជ្រៅ និងការស្ញើចសរសើរនៃប្រជាជាតិវៀតណាមចំពោះសម្តេច ចំពោះនយោបាយរបស់ព្រះអង្គ និងចំពោះការប្រយុទ្ធតស៊ូរបស់ទ្រង់ ក្នុងឋានៈជាមេដឹកនាំប្រជាជនខ្មែរដ៏ក្លាហាន» ។ អស់រយៈពេល៥ឆ្នាំក្រោយពីជំនួប (ជាមួយនឹងផាំ-យ៉ាំងដុង) នេះមកមេដឹកនាំហាណូយហើយនិងសីហនុមានទំនាក់ទំនងកក់ក្តៅ ប្រកបដោយសេចក្តីស្រឡាញ់រវាងគ្នាទៀតផង ។

តែបីបួនថ្ងៃប៉ុណ្ណោះ បន្ទាប់ពីផាំ-យ៉ាំងដុងបានសន្យាថាជួយគាំទ្រ (ស្តេចសីហនុ) ពួកកងកុម្មង់ដូយៀកកុង បានដើរចូលប្រសេចប្រសាចទៅភូមិនានានៅខាងកើតប្រទេសកម្ពុជា ដោយមានចែកត្រាក់ ដែលមានរូបសម្តេចសីហនុ ព្រមទាំងខ្សែអាត់ ដែលមានសម្លេងអំពាវនាវរបស់ទ្រង់ ស្រែកឲ្យប្រជាជនខ្មែរងើបឡើងតស៊ូ ។ ដោយសារតែប្រជាប្រិយភាពរបស់សម្តេចសីហនុជាមួយនិងប្រជាកសិករ ក៏មានមនុស្សចុះចូលរាប់រយពាន់នាក់ មកឲ្យវៀតណាមហ្វឹកហ្វឺនធ្វើជាកងទ័ពសីហនុ ដែលមានឈ្មោះថាខ្មែររំដោះ ។ ពួកគ្រូយុទ្ធសាស្ត្រវៀតណាមខាងជើងក៏បានបើកសាលាយោធាមួយនៅភាគខាងជើងឆៀងខាងកើត នៅខេត្តក្រចេះ ដើម្បីបង្ហាត់បង្រៀនពួកខ្មែរចំណូលថ្មីទាំងនេះ ។

នៅក្រោម «ខែលការពារ» ដែលសម្តេចសីហនុបានចាត់ទុកថា «ប្រកបដោយវីរភាពនិងប្រសិទ្ធិភាព» របស់វៀតណាមខាងជើង ពួកកងទ័ពខ្មែររំដោះ ក៏បានកើនឡើង ពីចំនួន៩,០០០នាក់កាលក្នុងឆ្នាំ១៩៧០ មកដល់បីម៉ឺននាក់នៅក្នុងឆ្នាំ១៩៧៥ ។ កាំភ្លើងធុនធ្ងន់ រថក្រោះ ព្រមទាំងទ័ពថ្មើរជើងរបស់វៀតណាមខាងជើង បានវាយកំទេចបំបាក់ឆ្អឹងកងទ័ពលន់-នល់ ដែលមានភារកិច្ចមក «រំដោះ» ស្រុក ដែលកាន់កាប់ដោយពួកខ្មែររំដោះ ។ នៅចុងឆ្នាំ១៩៧២, នៅពេលដែលពួកខ្មែរក្រហម ហើយនិងខ្មែររំដោះចាប់ផ្តើមធ្វើប្រតិបត្តិការដោយខ្លួនឯង ពេលនោះកងទ័ពលន់-នល់បានត្រូវវាយបាក់ឆ្អឹងខ្នងរួចទៅហើយ ដោយសារតែកងទ័ពជាផ្លូវការរបស់ក្រុងហាណូយ, ហើយភូមិភាពទឹកដីកម្ពុជាមួយចំនួនធំបានត្រូវគ្រប់គ្រងដោយពួកខ្មែរតស៊ូរួចទៅហើយដែរ» ។

(Brother Enemy - Ibidem- p.64-65-66)